គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៥ ចេញផ្សាយថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១
No. 5 Released on August 02, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# បរធនបាលកិច្ចសាធារណៈ

## Public Trust



រូបភាព | Picture: https://images.livemint.com/img/2020/06/30/600x338/Trust_1593534971030_1593534985786.jpg

បរធនបាលកិច្ចសាធារណៈត្រូវបានបង្កើតឡើង ក្នុងគោលបំណងជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរទូទៅ *(ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)*។ បរធនបាលកិច្ចនេះរួមមាន៖

**១.** ការអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅពេលដែល៖ **ក.** ដៃគូអភិវឌ្ឍផ្តល់ទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួនសម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ ហើយទ្រព្យសម្បត្តិឬមូលនិធិទាំងនោះបាននិងកំពុងគ្រប់គ្រង និងចាត់ចែងនៅក្នុងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុឬបុគ្គលផ្សេងទៀត និង **ខ.** តាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**២.** ជាប្រយោជន៍សាធារណៈផ្សេងទៀតនៅពេលដែលបញ្ញត្តិករពាក់ព័ន្ធតែងតាំងបរធនបាល ដើម្បីគ្រប់គ្រងនិងការពារមូលនិធិនានាតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ លក្ខខណ្ឌទាំងនេះមានជាអាទិ៍៖ **ក.** មូលនិធិដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាល ឬត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញគោលបំណងជាក់លាក់ណាមួយរបស់អ្នកផ្តល់ជំនួយ ហើយអ្នកផ្តល់ជំនួយទាមទារឱ្យមូលនិធិនេះ ត្រូវបានចាត់ចែងប្រើប្រាស់ និងអាស្រ័យផលស្របតាមគោលបំណងរបស់ខ្លួន ឬ **ខ.** ត្រូវការពារផលប្រយោជន៍របស់កុមារឬអសមត្ថជនផ្សេងទៀត ឬ **គ.** មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋតាមបទប្បញ្ញត្តិជាធរមាន។

Public Trust is established for the benefit of Cambodian citizens *(Law on Trust, 2019)*. This trust includes:

**1.** Development of the banking and microfinance sector in Cambodia when: **A.** Development partners provide their assets or funds for the benefit of the Cambodian citizens, and those assets or funds have been managed and administered in banking and microfinance institutions or other persons; and **B.** According to the conditions specified in the letter of trust or provisions in force.

**2.** For the other public interest, when the relevant regulator appoints a trustee to manage and protect the funds in accordance with the conditions specified in the letter of trust or provisions in force. These conditions include: **A.** Funds provided to the Royal Government or provided by the Royal Government of the Kingdom of Cambodia for the specific purpose of the donor, and the donor requires that the fund be administered, used and enjoyed in accordance with its intended purpose; or **B.** To protect the interests of children or other persons with disabilities; or **C.** Inheritance that falls into state property in accordance with the provisions in force.

**ឯកសារយោង | References**:
- ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.